((مَا خَلَقْنَاهُمَا إِلَّا بِالْحَقِّ وَلَكِنَّ أَكْثَرَهُمْ لَا يَعْلَمُونَ)) الدخان ٣٩

មានន័យថា: យើងគ្មានបង្កើតទេ ទាំងពីរវា (មេឃ, ផែនដី)

លើកលែងតែបង្កើតនោះ ដោយមានការពិតប្រាកដ ហើយក៏ប៉ុន្តែ មនុស្សភាគច្រើន ពុំបានយល់ដឹងឡើយ ។

ម្ចាស់ទ្រង់ក៏មានព្រះបន្ទូលបន្ថែមទៀតថា :

((وَمَا خَلَقْنَا السَّمٰوٰتِ وَالْأَرْضَ وَمَا بَيْنَهُمَا بَاطِلًا)) سورة : ص ،٢٧ .

មានន័យថា: ហើយយើងគ្មានបង្កើតនូវមេឃ ហើយនិងផែនដី ព្រមទាំងអ្វីៗសព្វសារពើទាំងអស់ ដែលស្ថិតនៅចន្លោះមេឃនិងផែនដី ដោយឥតការ ឥតន័យ: ឥតប្រយោជន៍នោះទេ ។

ទាំងអស់ពិភពលោក គឺស្ថិតនៅក្រោមអំណាចព្រះចេស្តា របស់ អល់ឡោះជាម្ចាស់ ពុំមានអ្វីៗណាមួយអាច គេចផុតពីការក្តាប់ដៃរបស់ ទ្រង់បានឡើយ ។ ដូចនោះហើយ មនុស្សទាំងឡាយ គោរពកោតខ្លាច អល់ឡោះជាម្ចាស់ទ្រង់ គឺគោរពប្រតិបត្តិតាមបញ្ជាច្រើ ហើយ ចៀសចេញមិនសន្ទិច នូវកិច្ចការណាដែលទ្រង់ហាមឃាត់ ។

ការបើកកជំពូក الفاتحة

សេចក្តីផ្តើម

ជំពូក الفاتحة នេះ ដែលមានឈ្មោះ ស៊ីបហាណាហ៊ីវ៉ាតារអាដឿ បានបញ្ចុះនៅម៉ាក្កះ ដោយមាន ៧ឃ្លា ។ ជំពូកនេះហើយដែលទ្រង់បានបញ្ចុះដំបូងគេ ដោយពោរពេញលក្ខណៈ នៅក្នុង គួរអាន ហើយជាដំបូងគេបង្អស់ អំពីបណ្តា ជំពូកផ្សេងៗទៀត ដែលទ្រង់បានបញ្ចុះនៅឯម៉ាក្កះនោះ ។

គេអោយឈ្មោះ الفاتحة នេះ ហេតុដោយជំពូកនេះហើយ គេបានចាប់ផ្តើមចងក្រង«គួរអាន» នឹងជំពូកនេះ ។

គេអោយឈ្មោះទៀត អ៊ុំមុលគួរអាន أم القران (កំពូលគួរអាន) ឬ អ៊ុំមុលគីតាប أم الكتاب (កំពូលគម្ពីរ) ដោយហេតុជំពូកនេះ ហាក់បីដូចជាបណ្តុំមូល នៃអត្ថន័យរបស់គួរអាន មិនថាផ្នែកណាមួយក្នុងការជឿ អាគីដ្យាយ នៃគួរអាននេះ ។

ហេតុដូចនេះ គេតម្រូវអោយសូត្រ الفاتحة ជំពូកនេះ ពេលថ្វាយបង្គំ (الصلاة)

គេបានអោយឈ្មោះជំពូកនេះទៀតថា អេសសាបអ៊ុលម៉ាសានី السبع المثاني ដែលមាន៧ឃ្លា ដោយហេតុគេសូត្រជំពូកនេះ សារចុះសារឡើងក្នុងការថ្វាយបង្គំ الفاتحة ជំពូកនេះពោរពេញទៅដោយអត្ថន័យ ដែលមានខ្លឹមសារ ចម្រុះចម្រាយ ហើយបានបញ្ជាក់ ទៅនឹងជំពូកដែលផ្សេងៗទាំងអស់ទៀតក្នុង គួរអាន ដូចជា:

- ជំនឿ .- គឺអោយយើងមានជំនឿជឿជាក់ថា អល់ឡោះនោះជាម្ចាស់តែមួយគត់ គ្មានគូ ដែលមានបញ្ជាក់ក្នុងជំពូកទី២ស្រាប់ ជំពូកនេះទៀតបានបញ្ជាក់ អំពី ការសរសើរ :
- ការសរសើរ .- គឺការគោរពសរសើរគ្រប់បែបគ្រប់យ៉ាង ហើយនឹងការថ្លែងអំណរគុណគ្រប់ជំពូក ទៅចំពោះ អល់ឡោះជាម្ចាស់ ក៏ដោយសារទ្រង់នេះហើយ ដែលបានបង្កើតក្តីសុខរុងរឿង (...) សព្វសារពើទាំងអស់ ក្នុងលោកនា

ក្នុងការជោគជ័យនេះ គឺ ការបង្កើត ការផ្តល់ផ្គង់ ហើយនិងការបង្កើនឡើងនូវ ជីវៈ វិញ្ញា ។

ការសាធារណ៍និងទេសនា បញ្ជាក់អំពីការលាតសាររបស់ព្រះអង្គ ដោយមិនរើសមុខ ទាំងអ្នកមានជំនឿ ហើយនិងអ្នកគ្មានជំនឿ នៅក្នុងលោកីយនេះ។

ការមេត្តាប្រណី ៖— បញ្ជាក់អំពីព្រះអង្គ ដែលមានការមេត្តាប្រណី ទៅដល់ចំពោះអ្នកដែលមានជំនឿក្នុងសាសនា នៃឋានបរលោកនាយ។

ការយុត្តិធម៌ ៖—បានបញ្ជាក់នូវការយុត្តិធម៌ ដ៏ឥតលំអៀង និងមហិទ្ធិឫទ្ធិ ទាំងពួងពិត ដែលមានសំណាងទទួលបានជឿយ៉ា ទៀតអំពីសភាពការ អាត់សេចក្តីនៅ ឋានទិព្វ បរលោក ។

សំណាងចេស្តា ៖— បានបញ្ជាក់នូវសំណាងព្រះចេស្តា របស់ព្រះអង្គ ហើយ និងបញ្ជាក់អំពីលក្ខណៈ ដែលទទួលខុសត្រូវរបស់យើងដ៏ទូទៅ អុលឡោះជាម្ចាស់ ។

និងនេះ ក្នុងបណ្ដូននេះ អុលឡោះបានបញ្ជាក់ បង្គាប់ប្រើយើងទាំងអស់គ្នាអោយសំពះទៅព្រះអង្គតែមួយគត់ ទៀតប្រើអោយយើងទាំងអស់គ្នា សុំជំនួយអំពីព្រះអង្គតែមួយគត់ដែរ ហើយទៀតបំរាម របស់ទ្រង់ មិនអោយយើងសំពះឬសុំអ្វីៗ នោះក្រៅអំពីទ្រង់ទៀតឡើយ ។

ការសុំវិថីត្រឹមត្រូវ ៖— បានបញ្ជាក់នូវលក្ខណៈដ៏ត្រឹមត្រូវ ដ៏ឥតលំអៀង របស់ព្រះអង្គ ទៀតព្រះអង្គបានបង្រៀន អោយយើងរាល់គ្នាសុំផ្លូវ ដែលត្រង់ត្រូវ អំពីព្រះអង្គ គឺផ្លូវ ដែលព្រះអង្គបាន អនុញ្ញាតិ យល់ព្រម

ផ្លូវដ៏ត្រឹមត្រូវ — បញ្ជាក់អំពីផ្លូវ ដែលព្រះអង្គប្រទានអោយទៅ ដល់អ្នកដែលគោរពតាមហើយ គឺជាផ្លូវដែលអ្នកកាន់សាសនា និងបណ្ដាមិត្តភក្តិ របស់គេទាំងនោះ ហើយគឺជាអ្នកប្រតិបត្តិ តាមផ្លូវរបស់អុលឡោះ ជាម្ចាស់ ហើយទៀតដែលកាត់ចេញផុតពីផ្លូវ ដែលព្រះអង្គ មានកំហឹង ទៅលើអ្នក ដែលគ្មានជំនឿនោះទេ ។

الفاتحة

ការបើក [illegible]

១. នឹងព្រះនាម អល់ឡោះ ម្ចាស់ទ្រង់ មហាសាធារណ៍ទៀតទ្រង់ មហា មេត្តាប្រណី ។	١ بِسْمِ ٱللَّهِ ٱلرَّحْمَٰنِ ٱلرَّحِيمِ
២. ការសសើរ ទាំងអស់នោះ ឆ្ពោះទៅ អល់ឡោះ ម្ចាស់ដែលគ្រប់គ្រង ទាំងអស់ ពិភពលោក ។	٢ ٱلْحَمْدُ لِلَّهِ رَبِّ ٱلْعَٰلَمِينَ
៣. អល់ឡោះ ម្ចាស់ទ្រង់ មហាសាធារណ៍ទៀត ទ្រង់ មហា មេត្តាប្រណី ។	٣ ٱلرَّحْمَٰنِ ٱلرَّحِيمِ
៤. អល់ឡោះ ជាស្តេច (កាន់សេចក្តី) នា ថ្ងៃ បរលោក ។	٤ مَٰلِكِ يَوْمِ ٱلدِّينِ
៥. ចំពោះទ្រង់ហើយ ជាម្ចាស់ដែល យើងខ្ញុំសំពះ ទៀតចំពោះទ្រង់ហើយ ដែលយើងខ្ញុំ សុំជំនួយ ។	٥ إِيَّاكَ نَعْبُدُ وَإِيَّاكَ نَسْتَعِينُ
៦. ចង្អុលបង្ហាញផ្លូវ ចំពោះយើងខ្ញុំ ផ្លូវណា ដែលត្រង់ត្រូវ ។	٦ ٱهْدِنَا ٱلصِّرَٰطَ ٱلْمُسْتَقِيمَ
៧. ផ្លូវនោះគឺ ដែលទ្រង់ប្រទានពរ ដោយ ស្នេហ៍ អ្នកទាំងនោះ ដែលពុំមែនជា ផ្លូវ ដែលទ្រង់ទោស ក់ហឹង លើអ្នកទាំងនោះ	٧ صِرَٰطَ ٱلَّذِينَ أَنْعَمْتَ عَلَيْهِمْ غَيْرِ ٱلْمَغْضُوبِ عَلَيْهِمْ

ហើយតាំងមិនដំណើរផ្លូវដែលវង្វេងទាំងនោះ
ឲ្យខ្ញុំទៀតឡើយ وَلَا الضَّالِّينَ

សូមទទួលពាក្យនេះ សំណូមពររបស់យើងខ្ញុំ آمِينَ

បិតកាប់វិត្ត

គោលការណ៍ដ៏សំខាន់ៗ នៅក្នុងវិត្ត អាល់ហ្វាទីហះ (سورة الفاتحة) នេះ បានបញ្ចេញនូវច្បាប់ទម្លាប់ក្នុងសាសនាអិស្លាម ទាំងនោះ មានបញ្ជាក់ច្រើនទៀត ក្នុងគម្ពីរ (មក្កា) បានបញ្ចប់យ៉ាងក្បោះក្បាយជាងនេះទៅទៀត បន្ទាប់ពីវិត្ត អាល់ហ្វាទីហះ (سورة الفاتحة) នេះ។

មនុស្សលោក   النّاس

កំណើតវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ហើយមាន ៦ ឃ្លា ។ គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលគេបានបញ្ចុះវគ្គ الفلق ។ ឈ្មោះ س [illegible] គេបានយកមកពីពាក្យសំខាន់ ដោយរាល់ៗឃ្លា នៅក្នុងវគ្គនេះ មានពាក្យ الناس បានន័យថា មនុស្សលោក ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

ម្ចាស់ព្រះអង្គបានបង្គាប់ទៅចំពោះ មនុស្សលោក ដើម្បីការពារខ្លួនអ្នកទាំងនោះ សុំពឹងព្រះអង្គ [illegible] ហើយ [illegible] បានចូលទៅដល់ក្នុងវិញ្ញាណរបស់មនុស្សលោក សំពីព្រោយបីសាចនិងមនុស្ស ។

النّاس

មនុស្សលោក

និងព្រះនាមអល់ឡោះ ម្ចាស់ព្រះអង្គមហាសប្បុរស ព្រះអង្គមហាមេត្តាករុណា ។   بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

១. ចូរអ្នកនិយាយថា (ឱណាពី មូហាំម៉ាត់) ខ្ញុំសុំការពារខ្លួនពីម្ចាស់ ដែលព្រះអង្គគ្រប់គ្រងលើមនុស្សលោក ។   ١ قُلْ أَعُوذُ بِرَبِّ النَّاسِ

២ (អល់ឡោះ) ជាស្តេចលើមនុស្សលោក ។   ٢ مَلِكِ النَّاسِ

៣. ជាម្ចាស់ ដែលមនុស្សលោកត្រូវគោរពសំពះ   ٣ إِلَٰهِ النَّاسِ

៤. សំពីព្រោយបីសាច ដែលលង់លើយ   ٤ مِن شَرِّ الْوَسْوَاسِ الْخَنَّاسِ

ដែលនាំសោយស ក្នុងនិងទ្រើម្រាយ ចិត្ត

៥ អ្នកនោះហើយ ដែលខ្សឹបខ្សៀវទៅសោយ ទៅក្នុងដើមទ្រូង មនុស្សលោក ។ — الَّذِي يُوَسْوِسُ فِي صُدُورِ النَّاسِ ٥

៦ ទាំងពីពពួក ជីណ អាល់ជិន (الجنة) និង មនុស្សលោក — مِنَ الْجِنَّةِ وَالنَّاسِ ٦

ចំណែកជាវគ្គ អាល់គួរអាន (القرآن) គេបានចាប់ផ្ដើមឡើងដោយ (الفاتحة) ដែលមានគោលការណ៍សំខាន់ៗ បញ្ជាក់ប្រាប់ទៅមនុស្សលោក

-- ជឿនិងស្គាល់ពីគុណធម្មៈ ដ៏ខ្ពស់ សោយទ្រង់ជាព្រះអាទិករ គ្រប់គ្រង ។

-- ទៀតគឺសុំជំនួយពីទ្រង់ ។

មិនខុសពីនោះទេ ដែលចំវគ្គ គួរអាន (القرآن) នេះវិញដែលត្រូវ (الناس) នេះផងដែរ ដែលមានសេចក្ដីបញ្ជាក់ប្រាប់ថា សោយមនុស្សលោក សុំការពារ ពីទ្រង់ នូវប្រការនានា ការគិតអាក្រក់ ដែលកើតក្នុងលោកនេះ ។

ភាគ្រីធៀបភ្លឺ الفلق

កប៉ាវិត្ត វិត្តនេះ គេបានបញ្ចុះ នៅម៉ាកាល់ ដែលមាន ៥ ឃ្លា គេបានបញ្ចុះវិត្តនេះ ក្រោយពីពេលដែល គេបានបញ្ចុះវិត្ត الفيل ឈ្មោះ الفلق មានន័យថា ភាគ្រីធៀបភ្លឺ ។ គេយកមករំលឹកពាក្យសំដី ដែលមាននៅក្នុងឃ្លាដំបូងបង្អស់ នៃ វិត្តនេះ ។

គេបាននាំពាក្យមាននីតិសូត្រ បករំពីឈ្មោះ អាប៊ូឃុត, អាត់គោវ៍មីហ្សឹ អាលោស វ៉ាទៀ អ៊ិគរ៉ាស់ តាន អារម៉ៀវ៍ ៖

ពិតប្រាកដ ព្រះនោះ វីលិលុលឡោះ សុលឡល្លហ៊ូអាឡៃហ៊ីវ៉ាសាល់-ឡាំ បានធ្វើពិធីបួងសួង (صلاة) ហើយ សាវៈ(សាត្វី)បាន សូត្រ វិត្ត الفلق និងវិត្ត الناس នៅក្នុងរយៈកាល ធ្វើដំណើររបស់គាត់ ។

គោលការណ៍ដ៏សំខាន់ក្នុងន័យរបស់វិត្ត

- អុលឡោះ បានបញ្ជា អោយ យើង សុំកំពាំង អំពីគ្រប់ គ្រាំ ពាំងអស់ អំពើដែលល្អក់កខ្វក់ អោយ យោ ។

الفلق

ភាគ្រីធៀបភ្លឺ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

ដោយព្រះនាម អុលឡោះ ម្ចាស់ទ្រង់មហា សាណារណ៍ ទៀតទ្រង់ មហា មេត្តាប្រណី ។

١ قُلْ أَعُوْذُ بِرَبِّ الْفَلَقِ

១ ចូរប្រសិទ្ធិ៍ពោះ (ឱណ មូហាំម៉ាត់) ខ្ញុំសូម-កំពាំង អំពី អុលឡោះ ម្ចាស់ទ្រង់បង្កើត នាពេលភាគ្រីធៀបភ្លឺ

២ អំពីការ កខ្វក់ នៅ ក្នុង លោក (خلق). ٢. مِنْ شَرِّ مَا خَلَقَ

៣ ហើយនិងអំពីការកខ្វក់នៃរាត្រី ពេលណាដែលងងឹត ។ ٣. وَمِنْ شَرِّ غَاسِقٍ إِذَا وَقَبَ

៤ ហើយនិងការកខ្វក់ របស់ស្រីទាំង អស់ ណាប ដែលកំពង់ ស្ដុះ មន្ត អាគមន៍ ទៅ ក្នុង ចំណង នីល្ប៉ ។ ٤. وَمِنْ شَرِّ النَّفَّاثَاتِ فِي الْعُقَدِ

៥ ហើយនិងអំពី ការដែល កខ្វក់ របស់អ្នក ឈ្នានីស ក្នុងពេលណាដែលវាបានឈ្នានីស ។ ٥. وَمِنْ شَرِّ حَاسِدٍ إِذَا حَسَدَ

បិតកប៉ៃវិត វត្ត الفلق បានបញ្ជាក់លើបណ្ដាអ្នកដែលមាន សេចក្ដីជឿ . ដើម្បីសោយបណ្ដាអ្នកទាំងអស់នោះ សុំកំពាំង និង ក្រលញ្ជាះ ជាម្ចាស់ អំពី ទាំងអស់នៃការដែលកខ្វក់ បោរ បោរ នៅក្នុងលោក ។

ភាពស្មោះត្រង់ الإخلاص

កម្រិតវិគ្គ វគ្គនេះ គេបានបញ្ចុះនៅម៉ាកាស់ ដែលមាន ៤ ឃ្លា។ គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الناس ឈ្មោះ الإخلاص ហើយសារៈសំខាន់របស់នៅក្នុងវគ្គនេះ បានបញ្ជាក់អំពី ការជ្រះស្អាត ស្មោះស ទៅម្ចាស់ ដែលមានតែមួយគត់ ប៉ុណ្ណោះ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

គេបានបញ្ជាក់ អំពីការស្មោះសទៅចំពោះម្ចាស់ដែលមានតែមួយគត់ ប៉ុណ្ណោះ ហើយបានបំបាត់គោលគំនិតរបស់ ពួកគ្រិស្តសាសនា ដែលចូលរួមទៅនឹង អល់ឡោះ ហើយក៏បានបញ្ជាក់ដែរថា ដោយពិតប្រាកដ គ្មានអ្វីៗណាដែលទៀត អាចប្រៀបផ្ទឹម ស្មើនឹងទ្រង់បានឡើយ។

الإخلاص

ភាពស្មោះត្រង់

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

ដោយព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហា ករុណាទៀតទ្រង់មហា មេត្តាបំផុត។

١- قُلْ هُوَ اللَّهُ أَحَدٌ

១. ចូរប្រាប់ទៅចុះ (ឱ.'មហាំម៉ាត់) អល់ឡោះ នោះហើយគឺម្ចាស់តែមួយគត់

٢- اللَّهُ الصَّمَدُ

២. អល់ឡោះ នោះហើយ ដែលពឹងនៅ ក្នុងលោក ទាំងពីរ។

(អល់ឡោះ) ពុំដែលនាំកើតប្រសូតបុត្រ ហើយនិងពុំដែលនាំស្អាតឱ្យលុត្តរណា ប្រសូតនោះទេ ។

٣ لَمْ يَلِدْ وَلَمْ يُولَدْ

ហើយគ្មាននរណាមួយ អាចនឹងប្រៀប ធៀបស្មើនឹងទ្រង់បានឡើយ ។

٤ وَلَمْ يَكُنْ لَّهُ كُفُوًا أَحَدٌ

បរិសុទ្ធភាពចិត្ត ចិត្តនេះ បញ្ជាក់ អំពីការសំដែងនូវការស្មោះ តទៅ ចំពោះ អល់ឡោះជាម្ចាស់ ដែលមួយគត់ និងមានតែឯង ។

អណ្ដាតភ្លើង اللّهب

កំណើតវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ៥ ឃ្លា ។
គេបានបញ្ចុះវគ្គនេះក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الفتح
ឈ្មោះ اللّهب មានន័យថា អណ្ដាតភ្លើង ។ គេយកមកពីពាក្យ
សំដី لهب ដែលមាននៅក្នុងឃ្លាទី ៣ នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

និពន្ធរឿងរបស់ឈ្មោះ អាប៊ូឡាហាប់ និងភរិយារបស់វា ដែលបានប្រឆាំងនឹង រ៉ស៊ូលុលឡោះ សុលឡល់ឡោហ៊ូអាឡៃហ៊ីវ៉ាសាល់ឡាំ ។ តាំងពីដោក់ប្តីប្រពន្ធនោះ ខ្លួនគេគិតពីបណ្ដាសា បញ្ចូលទៅនៅក្នុងឋាននរក ។ ឯចំណែកទ្រព្យសម្បត្តិរបស់ អាប៊ូឡាហាប់នោះវិញ ពុំអាចជួយ-ស្រោចស្រង់ ការបរាជ័យពីសំណាកវាបានឡើយ ។ ដូចនេះដែរ ការប្រឆាំងរបស់គេទាំងពីរនាក់ក៏គ្មានផលប្រយោជន៍អ្វីដែរ ។

اللّهب
អណ្ដាតភ្លើង

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

នឹងព្រះនាម អល់ឡោះ ម្ចាស់ដ៏មហាករុណាក្រៃលែង ម្ចាស់ដ៏មហាមេត្តាប្រណី ។

١. تَبَّتْ يَدَا أَبِي لَهَبٍ وَتَبَّ

១. អន្តរាយហើយទាំងពីរដៃ(អាប៊ូឡាហាប់) និងត្រូវបានវាក៏អន្តរាយដែរ-ហើយ ។

២. ពុំបានផលប្រយោជន៍ សំរាប់វាទេ អំពី ទ្រព្យសម្បត្តិ របស់វា និងការងារ ទៀតដែរ ដែលវាបានប្រឹងធ្វើសកម្មភាព ។	مَآ أَغْنَىٰ عَنْهُ مَالُهُ وَمَا كَسَبَ ٢
៣ វានោះ គង់តែនឹងចូលទៅក្នុង ឋាននរក ដែលកំពុង តែ ឆេះក្រហមឆ្អៅ ។	سَيَصْلَىٰ نَارًا ذَاتَ لَهَبٍ ٣
៤ ហើយនឹង ភរិយា របស់វានោះ ដែលដើរ ជាអ្នកនាំ សង្កត់ទូល ។	وَامْرَأَتُهُ حَمَّالَةَ الْحَطَبِ ٤
៥ នៅលើក របស់វា មានខ្សែ ធំពេញដោយ រីកខ្ចុំ ឃ្លាំងវីសប៉ុរ ។	فِي جِيدِهَا حَبْلٌ مِنْ مَسَدٍ ٥

បរិស្ត ទាក់ទងនឹង [illegible] នោះ បានបញ្ជាក់ ឲ្យដឹងពីការណ៍ បរាជ័យ ទាញទៅនឹង នៃគ្រួសារ របស់ អ្នកមាំ អ៊ីទ័ ស្តាប់ស្រុលស្រុងហើយវិនាស ត្រូវវិនាសទាំងស្រុង ។

ជំនួយ النَّصْرُ

កាហវិត្ត វិត្តនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ៣ ប្រយោគ។
គេបានបញ្ចុះវិត្តនេះ នៅម៉ាក្កាស់ ពីមុនពេល ដែលគ្រូវបញ្ចូលទៅ
នៅក្នុងគម្ពីរនៃវិត្ត នៅ ហ៊ិជ្ជីលាល់ វិត្តនេះគេបញ្ចុះបន្ទាប់ពីរូបរ
ពីវិត្ត التوبة ។

ឈ្មោះ النصر គេយកមកអំពីពាក្យ សំដី النصر មានន័យថា ជំនួយ
ដែលមាននៅក្នុង ប្រយោគ ដំបូងបង្អស់ នៃវិត្តនេះ ។

គោលការណ៍សំខាន់ក្នុងន័យរបស់វិត្ត

សន្យារបស់ អល់ឡោះជាម្ចាស់ ហ៍ និងផ្តល់ជំនួយនោះ មកដល់
យើង ពេលនោះហើយ អ្នកសាងនឹង បានជោគជ័យ ។

- បញ្ជា អំពីព្រះអង្គ ដើម្បីឲ្យយើង សំអាត ក៏ឲ្យយមានការធ្វើលហ៊ិន
ក៏ ស្ម័គ្រមួយទៅចំពោះព្រះអង្គ ហើយត្រូវឲ្យយមានការសរសើរ ទៅចំពោះព្រះអង្គ
ហើយដើម្បីសុំការអភ័យទោសទៅចំពោះព្រះអង្គ ពេលដែលមានហើយរក្សា
ក្នុងដែលទាក់ទាញឲ្យបរសប្បាយពីគោរពរជីត្ត ។

النَّصْرُ
ជំនួយ

នឹងព្រះនាមរបស់អល់ឡោះ ម្ចាស់ខ្ញុំ មហាសាធិតបំផុត មហា មេត្តាប្រណី ។	بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ
១. ពេលណាបានមកដល់ហើយ ជំនួយ ពី	١ إِذَا جَاءَ نَصْرُ اللَّهِ وَالْفَتْحُ

អល់ឡោះ ហើយនិងជ័យជំនះ។

២. ពេលនោះហើយ ឯងបាននឹងឃើញមនុស្ស លោក ចូលទៅក្នុងសាសនា អល់ឡោះ ជាហ្វូងៗក្រុមៗ

وَرَأَيْتَ النَّاسَ يَدْخُلُونَ فِي دِينِ اللَّهِ أَفْوَاجًا

៣. ដូច្នេះចូរឯងសូត្រទៅចុះ (មូហាំម៉ាត់) និងសរសើរ ទៅចំពោះ ម្ចាស់ឯង ហើយ សុំអភ័យទោស ទៅចុះ ពីព្រោះម្ចាស់ ដោយព្រោះថាទ្រង់ហើយ ជាម្ចាស់ដ៏ប្រោស អភ័យទោស ។

فَسَبِّحْ بِحَمْدِ رَبِّكَ وَاسْتَغْفِرْهُ إِنَّهُ كَانَ تَوَّابًا

បរិកថាវគ្គ . វគ្គនេះបានដាក់បញ្ជាក់នូវសញ្ញាគាត់ ចប់កិច្ចការ របស់ណាពី (ណាប៊ី) មូហាំម៉ាត់ ស៊ូលលឡលហ៊ូអាឡៃហ៊ីវ៉ាសាល្លាំ នោះ ជាម្នាក់ រសូល ដ៏ពិសេសនិងសម្រេចរបស់លោកហើយ ។

បណ្ដាអ្នកដែលគ្មានជំនឿ الكافرون

កាហ្វ៊ីរូនវគ្គ វគ្គនេះគេបានបញ្ចុះ នៅម៉ាក្កាស់ ដែលមាន ៦ ឃ្លា ។

គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الماعون

ឈ្មោះ الكافرون មានន័យថា បណ្ដាអ្នកដែលគ្មានជំនឿ ។

គេយកមកអំពីពាក្យសំដី الكافرون ដែលមាននៅក្នុងឃ្លាជាដំបូង បង្អស់ នៃ វគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

សិន្ម ម្ចាស់ដែល មូហាំម៉ាត់ រ៉ស៊ូលុលឡោះហ៊ូកាឡៃហ្គីសាល់ឡាំ ព្រមទាំងអ្នកដែលតាមគាត់ មានសាសនា នោះ ពុំដែលដូចម្ចាស់ដូច អ្នកគ្មានជំនឿនោះ សាសនាទេ ។

ហើយគេមិនទាន់ពិនិត្យក្នុងរ៉ស៊ូល ឯសាសនាអាងជាគេ ដ៏ដែលអ្នកគ្មានជំនឿ សាសនានោះឡើយ

الكافرون

បណ្ដាអ្នកដែលគ្មានជំនឿ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

ដោយព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហាសាណាណ៍ទៀតទ្រង់ មហាមេត្តាប្រណី

١ قُلْ يَٰٓأَيُّهَا الْكٰفِرُوْنَ

១ ចូរស្រដីទៅថា (មូហាំម៉ាត់) ថា! បណ្ដាអ្នកដែលគ្មានជំនឿ ទៅលើសាសនា (របស់អល់ឡោះ) ។

២. ខ្ញុំមិនសក្ការៈទេ អ្វីដែលអ្នកឯងទាំងអស់គ្នានេះកំពុងតែសក្ការៈ ។	٢ لَآ أَعْبُدُ مَا تَعْبُدُونَ
៣. ហើយអ្នកឯងទាំងអស់គ្នា គ្មានសក្ការៈទេ នូវអ្វីដែលខ្ញុំសក្ការៈ ។	٣ وَلَآ أَنتُمْ عَـٰبِدُونَ مَآ أَعْبُدُ
៤. ហើយខ្ញុំមិនធ្លាប់សក្ការៈទេ អ្វីដែលអ្នកទាំងអស់បានសក្ការៈនោះ ។	٤ وَلَآ أَنَا۠ عَابِدٌ مَّا عَبَدتُّمْ
៥. ហើយអ្នកឯងទាំងអស់គ្នា គ្មានសក្ការៈទេ អ្វីដែលខ្ញុំសក្ការៈ ។	٥ وَلَآ أَنتُمْ عَـٰبِدُونَ مَآ أَعْبُدُ
៦. សំរាប់អ្នកឯង សាសនាអ្នកឯង ហើយសំរាប់ខ្ញុំ សាសនាខ្ញុំ ។	٦ لَكُمْ دِينُكُمْ وَلِىَ دِينِ

បរិតកប្បវត្តិ វគ្គនេះបានឆ្លុះបញ្ចាំង នូវសភាពការណ៍ របស់សង្គម របស់ បណ្តាអ្នកដែលគ្មានជំនឿ ក្នុងការប្រឆាំងរបស់គេ ដើម្បីរោបរាលសាវ៉ៈ(ណាព្វី) មូហាំម៉ាត់ សូលឡលឡហូអាឡៃហ៊ីវ៉ាសាល្លាំ នោះ និងបង្ហាញ ក្នុងការកាត់ផ្តាច់ ពាក់ព័ន្ធនឹងសាសនារបស់ពួកគេ ។

ស្រះស្រង់ពោរពេញទៅដោយក្តី សុខដុមរមនា (كوثر)

الكوثر

កំណើតវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កះ ដែលមាន ៣ បន្ទូល ។

គេបានបញ្ចុះវគ្គនេះក្រោយពីពេលដែលគេបានបញ្ចុះវគ្គ العاديات ឈ្មោះ الكوثر នេះមានន័យថា សុខដុមរមនា ដែលច្រើន ។

គេយកមកអំពីពាក្យសំដី الكوثر ដែលមាននៅក្នុងបន្ទូលទីមួយ-បង្អស់នៃវគ្គនេះ ។

វគ្គនេះលើកទឹកចិត្តណាពី (ណាពី) មូហាំម៉ាត់ សូលលលហូអាឡៃហ៊ីវ៉ាសាល្លាំ ដើម្បីអោយបានក្តីសុខសប្បាយរីករាយ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

អល់ឡោះ បានប្រទានអោយគឺសុខដុមរមនា ជាច្រើន ហេតុដូចនេះហើយ ចូរសឹត និងធ្វើ បរាគសូត្រ(قربان) ចុះ ឱ! មូហាំម៉ាត់ ។ សង្ឃឹមថាក្នុងជាតិនេះ ដ៏មានការគាំទ្រយ៉ាងច្រើន រហូតទាល់តែដល់ថ្ងៃ បរលោក ហើយសង្ខេបនិង ឋានកិត្តិយសកេរ្តិ៍ឈ្មោះ ដ៏ខ្ពង់ខ្ពស់ល្អដាច់បំផុត នៅក្នុងឋានលោកនិងនៅឋាន បរលោក ។ ចំណែកឯវិញនោះ ពួកសត្រូវដែលប្រឆាំងរបស់ព្រះ ដែលល្អប់ឆ្ពឹមដ៏នោះទៀយ ។

الكوثر
ស្រះស្រង់ពោរពេញទៅដោយក្តី សុខដុមរមនា

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

និងព្រះនាម អល់ឡោះ ម្ចាស់ប្រណីមហាសាធារណ៍ ទៀតប្រណីមហាមេត្តាប្រណី

១. ពិតប្រាកដមែន យើងបានអោយទៅឯង ហើយ (ម៉ូហាំម៉ាត់) ស្រះមួយដែលពោរពេញ ទៅដោយភក្តី សុខុមង្គលប្បគា (កូសារ) | ١ إِنَّا أَعْطَيْنَاكَ الْكَوْثَرَ

២ ហេតុដូច្នេះ ចូរឯងគោរពសំពះថ្វាយបង្គំ (សំឡាត់) ទៅចំពោះម្ចាស់របស់ឯង ហើយនឹងបំពេញការលើយញ្ញ គួរ្បាន (قربان) ផង ។ | ٢ فَصَلِّ لِرَبِّكَ وَانْحَرْ

៣. ពិតប្រាកដ អ្នកដែលជាសត្រូវនឹងឯង នោះ ខ្លួនគេនិងកាត់ផ្តាច់ពូជ និងបុព្វហេតុ គាត់មិនមានឡើយ ។ | ٣ إِنَّ شَانِئَكَ هُوَ الْأَبْتَرُ

បើតាមប្រវត្តិ វគ្គនេះបានបង្រៀនអោយយើង ធ្វើកិច្ចប្រតិបត្តិ (عبادة) ទៅចំពោះអល់ឡោះ ហើយនិងធ្វើយញ្ញសត្វ (قربان) ដើម្បីអារក្សគាល់ បង្ហាញអោយឃើញការដឹងគុណ សរសើរ លើភក្តី សុខុមង្គលប្បគា (កូសារ) ដែល អល់ឡោះ បានប្រទានអោយមកដល់ យើង និងបានប្រទានច្រើន កិត្តិគុណ ។

របស់របរសំរាប់ប្រើប្រាស់   المَاعُون

កថាវិត្ត វិត្តនេះគេបានបញ្ចុះ នៅម៉ាក្កាល់ ដែលមាន ៧ បន្ទូ ។

គេបានបញ្ចុះវិត្តនេះ ក្រោយពីពេលដែលគេបានបញ្ចុះវិត្ត التكاثر ឈ្មោះ الماعون មានន័យថា របស់របរសំរាប់ប្រើប្រាស់ ។

គេយកឈ្មោះមកអំពីពាក្យសំដី الماعون ដែលមាននៅក្នុងបន្ទូទី ៧ នៃវិត្តនេះ

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វិត្ត

បញ្ជាក់ អំពីលក្ខណៈរបស់ មនុស្សលោកខ្លះៗ ដែលគេក្រឡេកមើលទៅ ហាក់បីដូចជាប៉ិតនៅក្នុង ការភូតភរក្បត់ទៅនឹងសាសនា ។

ការព្រងោះពិស ធៀលទៅដល់ បណ្ដាអ្នកដែលធ្វើនឹងថ្វាយបង្គំ (صلاة) ដោយភាពធ្វើរវាយ គ្មានសេចក្ដីស្មោះស ។

المَاعُون
របស់របរសំរាប់ប្រើប្រាស់

ដោយព្រះនាម អល់ឡោះ ម្ចាស់ដ៏មហា សាការុណ្យឡើតដ៏ មហា មេត្តាប្រណី ។   بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

១. តើឯងបានឃើញដែរឬទេ? (ឱ ! មូហាំម៉ាត់) អ្នកដែលភូតភរនឹងសាសនា ។   ١ أَرَأَيْتَ الَّذِي يُكَذِّبُ بِالدِّينِ

២ គឺជាគេនោះហើយ អ្នកដែលនោះឯង ដែលជា អ្នកច្រានបង់ ក្មេងកំព្រា ។   ٢ فَذَٰلِكَ الَّذِي يَدُعُّ الْيَتِيمَ

៣ ហើយអ្នកនោះឯង ពុំមានការយកចិត្ត ទុកដាក់ ជួយដល់ នូវ ចំណីអាហារ ទៅ ចំពោះ ជនដែលក្រីក្រ ។

៣. وَلَا يَحُضُّ عَلَىٰ طَعَامِ الْمِسْكِينِ

៤. ដើម្បីមានវិនាស ការលំបាក សំរាប់បណ្ដា អ្នកសំពះថ្វាយបង្គំ (صلاة)

៤. فَوَيْلٌ لِّلْمُصَلِّينَ

៥ ដោយសារអ្នកទាំងនោះ គ្មានខ្វល់ខ្វាយបរិហារ ក្នុងការសំពះថ្វាយបង្គំ (صلاة)

៥. الَّذِينَ هُمْ عَن صَلَاتِهِمْ سَاهُونَ

៦. អ្នកទាំងនោះ គ្មានបំពេញការលើយកចិត្ត សំរាប់សំដែងអោយមនុស្សលោកនោះឃើញ

៦. الَّذِينَ هُمْ يُرَاءُونَ

៧. ហើយអ្នកទាំងនោះ គ្មានភក្តី ក្នុងការលះ យកចិត្តនៃការបរិច្ចាគទាន (الزكاة)

៧. وَيَمْنَعُونَ الْمَاعُونَ

បរិយាយវិគ្គ ខគ្គ الماعون ក្ដានបញ្ជាក់យ៉ាងច្បាស់លាស់ អំពីលក្ខណៈ នៃមនុស្សលោក ដោយគន្លាក់ល្អក្ដល់ ដែលកើតមានឡើង បណ្ដាអ្នកទាំងនោះ គ្រោះមានកន្លងការបង្ហាញយ៉ាងប្រាកដបែបយ៉ាង ។

បណ្តាក្រុមគូរីស القريش

កថាវិគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ិកកាស់ ដែលមាន ៤ ឃ្លា ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ التين ។
ឈ្មោះ قريش មានន័យថា ក្រុមគូរីស ។
គេយកតាមពាក្យសំដី ដែលមាននៅក្នុងឃ្លាដំបូងបង្អស់ ។
ការបញ្ជាក់ ៖ បណ្តាក្រុមគូរីស គឺក្រុមដែលគេលើកដំកើង ហើយគេ ឧបត្ថម្ភសំណាក់ គោរពនិងរក្សា កាក់បាស់ (كعبة)

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

ការរំឭកទៅបណ្តាក្រុមគូរីស អំពី គុណូបការ (نعم) ដែលព្រះអល់ឡោះ ម្ចាស់ បានប្រទានទៅលើពួកគេទាំងនោះ ដូចនេះហើយ គេបានបញ្ជាឲ្យក្រុមគូរីសនេះឯង សំពះគោរពទៅចំពោះ អល់ឡោះ ម្ចាស់ ។

القريش

បណ្តាក្រុមគូរីស

ដោយព្រះនាមអល់ឡោះ ម្ចាស់ទ្រង់មហា ករុណាធិគុណទ្រង់មហា សព្វព្រហ្មគុណ ។ بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

១. ហេតុការណ៍ របស់ក្រុមគូរីស បានស្និទ្ធស្នាល ។ لِإِيلَافِ قُرَيْشٍ ١

២. គឺក្រុមទាំងនោះ បានស្និទ្ធស្នាលក្នុងការធ្វើ ដំណើរ នារដូវរងា និងរដូវក្តៅ إِيلَافِهِمْ رِحْلَةَ الشِّتَاءِ وَالصَّيْفِ ٢

٣ فَلْيَعْبُدُوا رَبَّ هَٰذَا الْبَيْتِ

៣ ទើប ចូរពួកគេទាំងអស់នោះ គោរពបូជា ទៅម្ចាស់នៃផ្ទះនេះ (كعبة)

٤ الَّذِي أَطْعَمَهُم مِّن جُوعٍ وَآمَنَهُم مِّنْ خَوْفٍ

៤ ទ្រង់ដែលបានប្រទាន ចំណីអាហារទៅ ឲ្យលើពួកគេទាំងអស់នោះ ដើម្បីបំបាត់ នូវការស្រេកឃ្លាន ហើយទ្រង់បានប្រទាន នូវសុខក្សេមក្សាន្ត ទៅឲ្យលើពួកគេទាំងនោះ ដើម្បីនឹងបំបាត់ នូវការខ្លាចកោតក្រែង ។

បឋិត គតិវិជ្ជា ៖ ពួក قريش បានបញ្ចេញ អំពីដំណើរការណ៍របស់គេ នៃក្រុមកូរៃស ព្រោះហេតុនេះ គេនឹងអាចគោរព នូវការជាប់ជាគ ទៅបណ្ដាអ្នកទាំងនោះ ដើម្បីនឹងទទួលប្រយោជន៍ផល ។

ដំរី الفيل

កំណើតវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ិកកាស់ ដែលមាន ៥ ឃ្លា ។

គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الكافرون

ឈ្មោះ الفيل មានន័យថា ដំរី ។

គេយកមកអំពីពាក្យសំដី الفيل ដែលមាននៅក្នុងឃ្លាទីមួយបង្អស់នៃវគ្គនេះ ។

ការបញ្ជាក់ វគ្គនេះបានបើកអាក ការនិទានដោយពិស្ដារនូវ អំពីកងទ័ព ដំរី មកពីស្រុកយេម៉ែន ដែលមានមេបញ្ជាការឈ្មោះ អ៊ីប្រហាំ ដោយមានគោលបំណងចង់មកវាយ កាក់បាស់នៅម៉ិកកាស់។ មូលហេតុកើតរឿងហ្នឹងនេះ នៅក្នុងកំណើតរបស់ ណាពី (ណាពី) មូហាំម៉ាត់ សុលឡលឡហ៊ូ អាឡៃហ៊ីវ៉ាសាល់ឡាំ នេះឯង ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

ការនិទាន អំពីកងទ័ព ដំរី ដែល អល់ឡោះ បានបញ្ចុះ ទារុណកម្ម យ៉ាងធ្ងន់ធ្ងរ ។

ដោយទ្រង់បានបញ្ជា កោយកងទ័ពអត្តលោប ចាំគាំបោកកំទេច អំពីឋាននរក យកមកទម្លាក់ប្រហារ និងកងទ័ពដំរីនោះ រហូតធ្លាក់ទៅស ម្តុកយ ដូចជា ស្លឹកឈើដែល សត្វ ស៊ី អស់រលីងអីចឹង ។

الفيل

ដំរី

بِسۡمِ اللّٰهِ الرَّحۡمٰنِ الرَّحِيۡمِ

នឹងព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហា អាណិតស្រឡាញ់ទ្រង់មហា មេត្តាប្រណី ។

១. តើអ្នកគ្មានបានសង្កេតមើល បើសិនជាម្ចាស់ទេ ?
ដោយរបៀបណាដែលម្ចាស់អ្នក ធ្វើចំពោះពួក
ម្ចាស់ដំរីនោះ ។

أَلَمْ تَرَ كَيْفَ فَعَلَ رَبُّكَ بِأَصْحَٰبِ ٱلْفِيلِ

២ តើទ្រង់មិនបានធ្វើ ? ល្បិចកលរបស់ពួកគេ
[illegible]
[illegible] ។

أَلَمْ يَجْعَلْ كَيْدَهُمْ فِى تَضْلِيلٍ

៣ ហើយ ម្ចាស់ បានបញ្ជូនហ្វូងបក្សី
[illegible] ។

وَأَرْسَلَ عَلَيْهِمْ طَيْرًا أَبَابِيلَ

៤ [illegible]
(ក្រួស) [illegible]
[illegible]

تَرْمِيهِم بِحِجَارَةٍ مِّن سِجِّيلٍ

៥ [illegible]
[illegible]
[illegible] ។

فَجَعَلَهُمْ كَعَصْفٍ مَّأْكُولٍۭ

ពិពណ៌នាវគ្គ វគ្គ الفيل បានបញ្ជាក់អំពីការបរាជ័យ [illegible] របស់
កងទ័ព និង ដំរី [illegible] មេបញ្ជាការ ឈ្មោះ [illegible] ។
ដោយសារ [illegible] (سجيل) [illegible]
[illegible] ។

១.

២.

អ្នកនិយាយដើមគេ　　الهمزة

កាំផ្ទៅទី វគ្គនេះ គេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ៩ ឃ្លា។ គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបញ្ចុះវគ្គ القيامة ឈ្មោះ الهمزة មានន័យថា អ្នកនិយាយដើមគេ។

គេយកពាក្យមកធ្វើជាសំដីថា الهمزة ដែលមាននៅក្នុងឃ្លាទី ១ ដើម្បីបង្ហាញនៃវគ្គនេះ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

អុលឡោះ បានគំរាមកំហែងទៅលើពួក អ្នកចូលចិត្ត ប្រមាថ មើលងាយគេ និងអ្នកដែលនិយាយដើមគេ ហើយមានចិត្តលោភលន់ ប្រមែប្រមូលទ្រព្យសម្បត្តិ ក៏ប៉ុន្តែ មិនព្រមចូលចិត្តបរិច្ចាគទាន សំរាប់នៅក្នុងផ្លូវ របស់ អុលឡោះ ជាម្ចាស់។

الهمزة
អ្នកនិយាយដើមគេ

ដោយព្រះនាម អុលឡោះ ម្ចាស់ដ៏មហាសប្បុរស ដ៏មហាមេត្តាករុណា។　　بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

១. គ្រោះហិនវិនាស សំរាប់ រាល់ៗអ្នកដែល ប្រមាថមើលងាយគេ និងអ្នកដែលនិយាយដើមគេ។　　١ وَيْلٌ لِّكُلِّ هُمَزَةٍ لُّمَزَةٍ

២. អ្នកដែលប្រមែប្រមូលទ្រព្យសម្បត្តិ ហើយ　　٢ الَّذِي جَمَعَ مَالًا وَعَدَّدَهُ

រវល់តែនឹងរាប់ទ្រព្យសម្បត្តិរបស់វា ។

៣. វាសង្ឃឹមគិតថា ពិតប្រាកដ ទ្រព្យសម្បត្តិ របស់វានេះ នាំឲ្យវាបានគង់វង្សរាប់ឆ្នាំ	٣ يَحْسَبُ أَنَّ مَالَهُ أَخْلَدَهُ
៤ កុំស្មានដូច្នោះឡើយ ពិតប្រាកដ គេនឹងបោះ បញ្ជូលទៅក្នុង ហ៊ូតោម៉ាស់ (الحطمة)	٤ كَلَّا لَيُنْبَذَنَّ فِي الْحُطَمَةِ
៥ តើអ្នកដឹងថាបាននឹងដឹងឬទេ? អ្វីទៅ ហ៊ូតម៉ាស់នោះ ។	٥ وَمَا أَدْرَاكَ مَا الْحُطَمَةُ
៦ នោះគឺ ភ្លើងរបស់ អល់ឡោះដែលគេបាន បញ្ឆេះឡើងក្រហម ។	٦ نَارُ اللَّهِ الْمُوقَدَةُ
៧. ភ្លើងដែលកំពុងឆេះនោះ តាមឡើងដល់ទីជម្រៅ ក្តៅ ទៅដល់ក្នុងចិត្ត ។	٧ الَّتِي تَطَّلِعُ عَلَى الْأَفْئِدَةِ
៨. ពិតប្រាកដ ភ្លើងនោះហើយ ដែលគេបាន គ្រួបដណ្តប់ ទៅលើអ្នកទាំងអស់នោះ ។	٨ إِنَّهَا عَلَيْهِمْ مُؤْصَدَةٌ
៩ រយៈកាលនោះ គេបាន ចងភ្ជាប់ អ្នកទាំងនោះ ទៅនឹងសសរដ៏វែង ។	٩ فِي عَمَدٍ مُمَدَّدَةٍ

ឋិត ក្នុងវគ្គ វគ្គនេះបានបញ្ជាក់ អំពីបណ្តាអ្នកដែលចូលចិត្ត ប្រមាថ មើលងាយគេ និងចូលចិត្តនិយាយដើមគេ ហើយ ម្យ៉ាងទៀតមានចិត្ត លោភលន់ប្រមឹងប្រមូលទ្រព្យសម្បត្តិ ដោយមិនយល់ថា

ប្រមូលសម្បត្តិនោះផងហើយ ទើបលក់ទោយខ្លួនវា បានជីតជេរបេរ-
កាល ។ ព្រោះតែខ្លួនឈរ បានជាវាត្រូវធ្លាក់ ទៅវិនាសអន្តរាយផ្លូវរបស់
ក្រលច្បោះព្រៃ ។ ដែលនេះហើយ ព្រាហ្មណ៍ជាជាតិចោរ ម្ដងទៀត
នឹងបានមនុស្ស ករុណាកម្ម ដ៏ឧបាកម្មចោរ មិនបានឡើយ ៕

ពេលវេលា العصر

កបិវវិគ្គ វិគ្គនេះគេបានបញ្ចុះនៅម៉ិកកាស់ ដែលមាន ៣ ឃ្លា ។
គេបានបញ្ចុះវិគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវិគ្គ
الم نشرح

ឈ្មោះ: العصر មានន័យថា ពេលវេលា
គេបានដកស្រង់ពីពាក្យសំដីថា العصر ដែលមាននៅក្នុងឃ្លាទីមួយ
មកដាក់ឈ្មោះនៃវិគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វិគ្គ

បណ្តាមនុស្សដែលរស់នៅក្នុងលោកនេះ ស្ថិតនៅក្នុងការខាតបង់នៃ
បានប្រយោជន៍ ក៏ឡើយ ពីព្រោះពេលណាអ្នកទាំងនោះ គ្មានបានបំពេញ
នូវ ពេលវេលា នឹងប្រព្រឹត្តការល្អប្រសើរ ។

العصر
ពេលវេលា

នឹងព្រះនាម អល់ឡោះ ម្ចាស់ដ៏មហា ករុណា ទៀតដ៏មហា មេត្តាប្រណី ។	بِسْمِ اللَّهِ الرَّحْمَنِ الرَّحِيمِ
១ អល់ឡោះជាម្ចាស់បានស្បថនឹងពេលវេលា ។	١ وَالْعَصْرِ
២ ពិតប្រាកដ មនុស្សលោក ទាំងអស់ស្ថិត នៅក្នុងការខាតបង់ធាតុ ។	٢ إِنَّ الْإِنسَانَ لَفِي خُسْرٍ

٣ إِلَّا الَّذِينَ آمَنُوا وَعَمِلُوا الصَّالِحَاتِ وَتَوَاصَوْا بِالْحَقِّ وَتَوَاصَوْا بِالصَّبْرِ

៣ វៀរលែងតែបណ្ដាអ្នកទាំងឡាយណា មានជំនឿជឿជាក់ ហើយបានប្រកបកិច្ចការល្អត្រឹមត្រូវ ទៀតអ្នកទាំងនោះសុទ្ធតែបានដាស់តឿនគ្នា ទៅការពិតប្រាកដ ហើយទៀតបានដាស់តឿនគ្នា ទៅការអត់ធ្មត់ ។

ឋិត ក្នុងវគ្គទី៣ វគ្គនេះបានបញ្ជាក់ថា មនុស្សណាៗក៏ដោយដែលមិនបានប្រើពេល ដោយអ្នកនោះមិនបានបំពេញការល្អប្រកិច្ចល្អនោះ គេចាត់ទុកថា អ្នកនោះខាតហើយ គឺអ្នកដែលខាតបង់ ពេលបានប្រើពេលឥតប្រយោជន៍ ។

ការលើកដំកើងខ្លួន التكاثر

កថាវគ្គ វគ្គនេះគេបានបញ្ចុះនៅ ម៉ាក្កាស់ ដែលមាន ៨ ឃ្លា ។

គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الكوثر ។

ឈ្មោះ التكاثر មានន័យថា ការលើកដំកើងខ្លួន ។

គេយកមកអំពីពាក្យសំដី التكاثر ដែលមាននៅក្នុងឃ្លាទីមួយបង្អស់នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

មនុស្សលោកដែលរស់នៅ ស្លិតក្នុងការលើកដំកើងខ្លួន ដោយខ្ពស់ជិតគេឯង នៅក្នុងសង្គមមនុស្សជាតិលោកនេះ រវល់តែប្រជែងដែលនាំ-ឲ្យ អ្នកនោះឯងវង្វេងផ្លូវ ភ្លេចនៅពេលដែលខ្លួនត្រូវធ្វើដំណើរទៅ ឲ្យបាត់បារម្ភ របស់មនុស្សលោក គង់តែនឹងភ្ញាក់ខ្លួនទេ គឺនៅពេលណាដែល មលាអ៊ីក (ملك عزرائيل) មកដកយកវិញ្ញាណខ្លួននោះ បានមកដល់ ។

គេមិនដឹងគេទេ នៅថ្ងៃបរលោក (الآخرة) នោះ គេនឹងសួរទៅអ្នកនោះឯង អំពី ក្ដីសុខសប្បាយ (نعيم) ដែលម្ចាស់ទ្រង់បានប្រទានឲ្យគេ រួចហើយក្នុងលោកិយ (الدنيا) នេះ ។ ដូច្នេះហើយនៅសាលយកការប្រមាណ ក្ដីសុខសប្បាយ នោះ នៅប្រើក្នុងការលើកដំកើងខ្លួន ដែលនាំឲ្យបាត់បង់ ភ្លេចផ្លូវ ពីព្រះប្រាថ្នា របស់អល់ឡោះ ។

التكاثر

ការលើកដំកើងខ្លួន

នឹងព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មេត្តា بسم الله الرحمن الرحيم

សាតារក់ទៀតរួមវត្ថុបាកមេត្តាប្រណី ។

Khmer	Arabic	
១. ការលើកដើមកើនឡើងនោះ នាំអោយបណ្ដា អ្នកឯងភ្លេចប្រឹងប្រែង (ក្នុងការគោរពគុណល្អោះ)	أَلْهَاكُمُ التَّكَاثُرُ	١
២. រហូតដល់ពេលបណ្ដាអ្នកឯង ចូលទៅក្នុង រណ្ដៅខ្មោច ។	حَتَّىٰ زُرْتُمُ الْمَقَابِرَ	٢
៣ ចូរកុំប្រព្រឹត្តដូចនោះអី បណ្ដាអ្នកឯងមុខជា- នឹងបានដឹងទេ ។	كَلَّا سَوْفَ تَعْلَمُونَ	٣
៤ បន្ទាប់មក ចូរបណ្ដាអ្នកឯងកុំប្រព្រឹត្តដូចនោះ ទៀតអី អ្នកឯងមុខជានឹងបានដឹងទេ ។	ثُمَّ كَلَّا سَوْفَ تَعْلَمُونَ	٤
៥ ចូរកុំប្រព្រឹត្តដូចនោះអី បើប្រសិនណាបណ្ដា អ្នកឯងបានដឹង ដោយវិជ្ជាយ៉ាងច្បាស់លាស់ ។	كَلَّا لَوْ تَعْلَمُونَ عِلْمَ الْيَقِينِ	٥
៦. ពិតប្រាកដណាស់ បណ្ដាអ្នកឯងនឹងបានឃើញ ឋាននរក ជាមិនខានឡើយ ។	لَتَرَوُنَّ الْجَحِيمَ	٦
៧. បន្ទាប់មក ពិតប្រាកដ បណ្ដាអ្នកឯងនឹងបាន ឃើញវា ដោយច្បាស់លាស់ នឹងភ្នែកក្បាល	ثُمَّ لَتَرَوُنَّهَا عَيْنَ الْيَقِينِ	٧
៨. បន្ទាប់មក ពិតប្រាកដមែន បណ្ដាអ្នកឯងនេះ នឹងត្រូវសួរ នៅថ្ងៃនោះ អំពីការសោកសប្បាយ ដែលល គុណល្អោះ ទ្រង់បានប្រទានអោយមក ហើយនោះ ។	ثُمَّ لَتُسْأَلُنَّ يَوْمَئِذٍ عَنِ النَّعِيمِ	٨

បិត គប់ាវត្ថុ វត្ថុនេះ ក្រោមតាំង បញ្ចាក់ខ្ញុំថា ប ធ្លះ បង្ហាញ និងការ
គ្រោះ តិសរៀល ទៅដល់កោះ អ្នកដែលលើកដីកើឡើង ហើយ
និង ក្តី សុខទុក្ខ ... ដែលប្រាប់ ក្រោយ ... ហើយក
ការទាយ ... សម្បត្តិ នោះ ទៅ ទីកោះ ... របស់អ្នកលក់ ។
ហេតុដូចនេះ អ្នកទាំងអស់គ្នា ឱ្យស្គាល់ ... ហើយ
... និង ស្នូរ មិនមានទៀយ សំលើការលើកដីកើឡើង ខ្លួនរបស់កោះ ។

ថ្ងៃគោះកាល الْقَارِعَةُ

កម្រងវគ្គ វគ្គនេះគេបានបញ្ចុះនៅ ម៉ាក្កាស់ ដែលមាន ១១ឃ្លា ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ قريش ។
ឈ្មោះ ១ឃ្លាកាត់ន័យថា ថ្ងៃគោះកាល ។
គេយកមកធ្វើជាក្បាលនិង ១ឃ្លា ដែលនៅក្នុងឃ្លាដំបូងរបស់វគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

វគ្គនេះ គេបានបញ្ជាក់ អំពីព្រឹត្តិការណ៍ នៅនាថ្ងៃគោះកាល ។
ថ្ងៃនោះសិង បណ្ដាមនុស្សលោក ដែលជ្រួតជ្រាបព្រាត និងបណ្ដា ភ្នំ (ភ្នំ) រសាត់ អណ្ដែតរញ្ជួយព្រាត តាមសាកសពរៀបរាប់ ពេលនោះ ហើយដែលថាថ្ងៃ ដែលគេថ្លឹងទម្ងន់នូវអំពើប្រព្រឹត្តិ របស់មនុស្សលោកដើម្បី ដែលបាន អនុវត្តិរួចមកហើយ គឺរបៀបៈពេលណោះដែរ គេក៏បានតបស្នង ហើយសមលោកនូវផល អំពី អំពើដែល មនុស្សលោកបានប្រព្រឹត្តិរួចពី មានលោកនី រួចមកហើយនោះ ។

الْقَارِعَةُ
ថ្ងៃគោះកាល

ដោយព្រះនាម អល់ឡោះ ម្ចាស់ទេសមហា សប្បុរសស្រឡាញ់ទេសមហា មេត្តាប្រណី ។

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

១. ថ្ងៃគោះកាល ។

١ الْقَارِعَةُ

٢ مَا الْقَارِعَةُ

២ អ្វីទៅ ថ្ងៃគោះកាលនោះ ?

٣ وَمَا أَدْرَاكَ مَا الْقَارِعَةُ

៣ តើអ្នកឯង ដឹងដែរឬទេ . អ្វីទៅថ្ងៃគោះ កាលនោះ ?

٤ يَوْمَ يَكُونُ النَّاسُ كَالْفَرَاشِ الْمَبْثُوثِ

៤. គឺថ្ងៃនោះឯង មនុស្សលោក មានភាពដូចជា មេអំបៅដែលកំពុងតែហោះ ហើរ ។

٥ وَتَكُونُ الْجِبَالُ كَالْعِهْنِ الْمَنْفُوشِ

៥ ហើយភ្នំទាំងឡាយ ប្រែក្លាយដូចជារោម ដែលកំពុងរសាត់តាមខ្យល់ ។

٦ فَأَمَّا مَنْ ثَقُلَتْ مَوَازِينُهُ

៦. ទើបជននោះ ចំពោះនរណា មានទម្ងន់ធ្ងន់ ការថ្លឹងរបស់អ្នកនោះ (អំពើល្អច្រើន)

٧ فَهُوَ فِي عِيشَةٍ رَاضِيَةٍ

៧. ទើបបាននិងជននោះ អ្នកនោះឯង និងបានរស់នៅក្នុងជីវិតពេញចិត្ត ។

٨ وَأَمَّا مَنْ خَفَّتْ مَوَازِينُهُ

៨. ហើយចំពោះនរណា មានទម្ងន់ស្រាលក្នុង ការថ្លឹងរបស់អ្នកនោះ (អំពើអាក្រក់)

٩ فَأُمُّهُ هَاوِيَةٌ

៩. ទីលំនៅ អ្នកនោះ គឺឋាននរកនោះឯង គឺឋាននរក ហាវីយ៉ាស (هاوية) ។

١٠ وَمَا أَدْرَاكَ مَا هِيَهْ

១០ តើអ្នកឯង បានដឹងដែរឬទេ អ្វីទៅឋាននរក ហាវីយ៉ាស (ماهية) នោះ ?

១១. នោះគឺកន្លែងភ្លើង ដែលមហាសែនក្តៅ ។ نَارٌ حَامِيَةٌ ١١

បិទ កថាវគ្គ វគ្គនេះបានបញ្ជាក់អំពីហេតុការណ៍ដែលគង់តែនឹង កើតមានឡើង នៅថ្ងៃនោះកាល ។

ហ្វូងសត្វសេះដែលមានល្បឿនក្នុងសង្គ្រាម العاديات

គម្ពីរទី វគ្គនេះគេបានបញ្ចុះ នៅម៉ាក្កាស់ ដែលមាន ១១ ឃ្លា ។

គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ العصر ។

ឈ្មោះ العاديات មានន័យថា ៖ ហ្វូងសេះដែលមានល្បឿនលឿនក្នុងសង្គ្រាម ។

គេយកមកដាក់ពាក្យសំដី العاديات ដែលមាននៅក្នុងឃ្លាទី ១ មកធ្វើជាឈ្មោះនៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

បញ្ជាក់អំពីការគ្រប់គ្រង និងការតាមឃ្លាំមើលរបស់អល់ឡោះជាម្ចាស់ ទៅលើពួកបណ្ដាមនុស្សលោក ដែលជាអ្នកប្រឆាំង និងមិនព្រមអនុវត្តតាម ព្រោះអ្នកទាំងនោះមានចិត្តលោភលន់ ស្រឡាញ់ទ្រព្យសម្បត្តិ ហួសហេតុ ។ ពិតប្រាកដណាស់ អ្នកទាំងនោះនឹងត្រូវតែទទួលនូវលទ្ធផល យ៉ាងសមហេតុសមផល នៅពេលណាគេបានបញ្ចេញអ្នកទាំងអស់នោះ អំពីផ្នូររបស់គេ ហើយពេលនោះទៀត អ្វីៗដែលនៅក្នុងដួងចិត្តរបស់អ្នកទាំងនោះ នឹងបញ្ចេញដោយអ្នកណាម្នាក់ ឃើញមិនខានឡើយ ។

العاديات

ហ្វូងសត្វសេះដែលមានល្បឿនលឿនក្នុងសង្គ្រាម

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

និងព្រះនាមអល់ឡោះ ម្ចាស់ដ៏មហា សាការលើ ទៀតស្រលាញ់ មហាមេត្តាប្រណី ។

وَالْعَادِيَاتِ ضَبْحًا ١

១ បានស្បថហើយ (អល់ឡោះ) ទៅនឹងពួកសត្វសេះចម្បាំងដែលបញ្ចេញសម្លេង

ដំណើរយ៉ាងលឿន ។

២ នាពេលនោះបានចេញភ្លើងហើយ ភ្លឺផ្លេក (ពីក្រចករបស់វា)

٢ فَالْمُورِيَاتِ قَدْحًا

៣ រួចនាពេលនោះ វាបានបោល សំរុក វាយប្រហារ ខ្មាំងយ៉ាងពេញទំហឹង នាពេលទៀបភ្លឺ ។

٣ فَالْمُغِيرَاتِ صُبْحًا

៤ ហើយនឹងពេលនោះទៀតទើប វាបានបញ្ចេញធូលី ធ្វើអោយដី ហុយខ្ទរពេញ ។

٤ فَأَثَرْنَ بِهِ نَقْعًا

៥. ទើបនាពេលនោះទៀត វាបានសំរុកចូល ទៅដល់ កណ្តាលទីលានប្រយុទ្ធ របស់ខ្មាំង ។

٥ فَوَسَطْنَ بِهِ جَمْعًا

៦. ពិតប្រាកដ មនុស្សលោកនោះឯង បានប្រព្រឹត្ត អំពើទុច្ចរិត ចំពោះម្ចាស់ ។

٦ إِنَّ الْإِنْسَانَ لِرَبِّهِ لَكَنُودٌ

៧. ហើយពិតប្រាកដ លើអំពើប្រព្រឹត្តដូច នោះឯងប្រាកដ មុខជាវានឹងបានឃើញវា មិនខានឡើយ ។

٧ وَإِنَّهُ عَلَىٰ ذَٰلِكَ لَشَهِيدٌ

៨ ហើយទៀត ពិតប្រាកដ មនុស្សលោកនោះ ឯង ជាអ្នកមហាកំណាញ់ ដោយ ភោគទ្រព្យ អំពើស្វះស្វែងទ្រព្យសម្បត្តិ ហួសហេតុពេក ។

٨ وَإِنَّهُ لِحُبِّ الْخَيْرِ لَشَدِيدٌ

៩. តើវាពុំដឹងទេឬ? ពេលណាទៅគេការ បង្កើតចេញ នូវអ្វីៗដែលនៅក្នុងផ្នូរ ។

أَفَلَا يَعْلَمُ إِذَا بُعْثِرَ مَا فِي الْقُبُورِ

១០ ហើយគេបានលាតត្រដាង នូវអ្វីៗដែលលាក់ទុ កំបាំង នៅក្នុងទ្រូង ។

وَحُصِّلَ مَا فِي الصُّدُورِ

១១ ពិតប្រាកដ ម្ចាស់ពួកគាត់របស់គេ នៅក ថ្ងៃនោះហើយ ទ្រង់ដែលឈ្លាសយ៉ាងជាប្រាកដ នូវអ្វីៗដែលពួកគាត់នោះ បានប្រព្រឹត្ត

إِنَّ رَبَّهُمْ بِهِمْ يَوْمَئِذٍ لَخَبِيرٌ

បិត កថាវត្ថុ វគ្គនេះបានបញ្ជាក់ សំដៅ លក្ខណៈ អកតញ្ញូ របស់ មនុស្សលោក និងការបង្ហៀកសំដីរ ទ្រព្យម្ហូបនិង ការតបស្នង នូវលទ្ធផល ទៅដល់នោះមនុស្សលោក នាពេលថ្ងៃនេះកាល នេះដែរ ។

ការរំជួយ الزَّلْزَلَة

កំណើតវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាឌីណាស់ ដែលមាន ៨ ឃ្លា។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ النساء
ឈ្មោះ ជ្ជាល្ហាល الزلزال មានន័យថា ការរំជួយ
គេយកពាក្យនេះពីពាក្យសំដី زلزال ដែលនៅក្នុងឃ្លាដំបូងបង្អស់
នៃវគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

បញ្ជាក់អំពី ការកើតរំជួយផែនដី នៅថ្ងៃគេះកាល (يوم القيامة) នោះ ដល់ថ្ងៃ មហាកក្រើករំជួយយ៉ាងខ្លាំង ។ នៅថ្ងៃនោះឯង បណ្ដាមនុស្សលោកទាំងអស់ មានសភាពស្ញែងស្ញើ គិតដឹងមិនបានអ្វីឡើយ ដោយសារតែមកពីមានការភិតភ័យ តក់ស្លុត អំពីសភាពការណ៍នៃថ្ងៃគេះកាលនោះឯង ។ ថ្ងៃនោះហើយគេបានប្រមូលអំពើ ទាំងអស់អំពីបណ្ដាមនុស្សទាំងពីរប្រភេទ ដើម្បីនឹងវិនិច្ឆ័យ កាត់សេចក្ដីនូវចំណុះក្នុងបញ្ជី របស់ពួកគេទាំងអស់នោះ។

الزَّلْزَلَة

ការរំជួយ

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

នឹងព្រះនាម អល់ឡោះ ម្ចាស់ដ៏មហា
សប្បុរស ម្ចាស់ដ៏មហា មេត្តាករុណា ។

١ إِذَا زُلْزِلَتِ الْأَرْضُ زِلْزَالَهَا

១ ពេលណាគេបានរំជួយហើយផែនដី
ទៅដោយរំជួយខ្លាំងរបស់វា (ផែនដី) ។

٢ وَأَخْرَجَتِ الْأَرْضُ أَثْقَالَهَا

២. ហើយផែនដី បានបញ្ចេញហើយ នូវ
និងលទ្ធផលក្នុងវាទាំងនោះ ។

٣ وَقَالَ الْإِنْسَانُ مَا لَهَا

៣ បានពោលថា ហើយមនុស្សលោក
ហេតុដូចម្ដេច បានជាផែនដី កើតមាន
រញ្ជួយដូចនេះ? ។

٤ يَوْمَئِذٍ تُحَدِّثُ أَخْبَارَهَا

៤. នៅថ្ងៃនោះ ផែនដី នឹងនិទានរឿងរ៉ាវដែល
កកើតមានរឿងនៅលើវានោះ ។

٥ بِأَنَّ رَبَّكَ أَوْحَىٰ لَهَا

៥. ដោយហេតុតែព្រះជាម្ចាស់អ្នកបាន
បញ្ជាទៅលើវា ។

٦ يَوْمَئِذٍ يَصْدُرُ النَّاسُ أَشْتَاتًا لِيُرَوْا أَعْمَالَهُمْ

៦. នៅថ្ងៃនោះ មនុស្សលោកនឹងបានចេញ
(ពីផ្នូររបស់គេ) ជាពួកៗក្រុមៗ ក្នុង
លក្ខណៈខ្ចាត់ខ្ចាយបែកបាក់ ដើម្បីគេ
នឹងបង្ហាញអ្នកទាំងអស់នោះ ពីអំពើខ្លួន
ដែលអ្នកទាំងនោះបានប្រព្រឹត្តរួចមក ។

٧ فَمَنْ يَعْمَلْ مِثْقَالَ ذَرَّةٍ خَيْرًا يَرَهُ

៧. ដូច្នេះ អ្នកណាៗ ហើយដែលបាន
ប្រព្រឹត្ត ការល្អ ទោះបីស្មើនឹងទម្ងន់
ហ្ស៊ែរ៉ស់ (ចំ.ដ. , ធូលីដីល្អិត) វានឹងបាន
ឃើញហើយ ការល្អរបស់គាត់ ។

٨ وَمَنْ يَعْمَلْ مِثْقَالَ ذَرَّةٍ شَرًّا يَرَهُ

៨. ហើយអ្នកណាៗហើយ ដែលបានប្រព្រឹត្ត
ការអាក្រក់ ទោះបីស្មើនឹងទម្ងន់ហ្ស៊ែរ៉ស់(ចំ.ដ.)

ធូលីដីស្អិតជាប់នឹងប្រាណបៃតងពាស អាក្រក់របស់
វានោះ ។

ឋិតកប៉ិចវិវត្ត ភ្នែកនេះមានបញ្ចាក់ សំភ្លឺប្រនារៗ ភ្លាមគាប់ ងោរា
ដីប្រូងបន្លាស នៅក្នុង ពេលកាលនោះ ។
នៅក្នុងនោះហើយ មនុស្សលោក គង់ដែងនឹងបាន ឃើញដោយងាយស្រួល
ខ្លួនឯង សំលៀកបំពាក់ដែលសក្ការរបស់នោះ មានប្រាសាទភ្នំប្រូយហើយ
នោះ ល្អ ឬ អាក្រក់ ខ្លួនឯងនឹងគ្រប់សំពត់ធូលី នោះក៏ដោយ ។

ភស្តុតាងដ៏ច្បាស់លាស់ البيّنة

កថាវត្ថុ ជំពូកនេះគេបានបញ្ចុះនៅមទីណះ ដែលមាន ៨ បទ ។

គេបានបញ្ចុះជំពូកនេះ ក្រោយពីពេលដែលគេបញ្ចុះជំពូក الطلاق ។

ឈ្មោះ البينة មានន័យថា ភស្តុតាងដ៏ច្បាស់លាស់ ។

គេយកមកសំដៅពាក្យសំដី البينة ដែលនៅក្នុងបន្ទាត់ទីមួយបង្អស់ នៃជំពូកនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វា

គេបញ្ជាក់ សំដីការអាក់ខ្ពង់នៃពួកគ្រូបណ្ឌិតគម្ពីរ ហើយនិងពួកអ្នកដែលថ្វាយបង្គំ (ម៉ូសរីគីន) ។ ដោយហេតុថា ពួកអ្នកទាំងនោះ ពុំព្រមលះបង់បាតចេញសំដីសាសនារបស់គេ រៀងៗខ្លួនឡើយ ។ រហូតដល់តែ សារ:(ពាក្យ) បានមកដល់អ្នកទាំងនោះ ដែលគួរច្បាស់បានលស្សារួចមកហើយ ។ ប៉ុន្តែពេល សារ:(ពាក្យ) បានដល់មក អ្នកទាំងអស់នោះ គឺបែកបាក់សាច់ជំលោះគ្នា ។ មានពួកខ្លះក៏មានជំនឿជឿតាម សារ:(ពាក្យ) ពួកខ្លះទៀតក៏បែរចេញគ្មានជំនឿនឹងសារ:(ពាក្យ) នេះ ។

ដំណើរការណ៍ នៃលក្ខណ: របស់សារ:(ពាក្យ) ដែលបានដល់មកនោះ ដោយសារបុព្វហេតុសមផល នៅតាមលក្ខណ: អ្នកទាំងអស់នោះ បានដឹងស្គាល់ តាមគម្ពីរ របស់គេរួចស្រេចមកហើយ ។ ហើយទៀតសារ:(ពាក្យ) បាននាំមក នូវការខ្វះខាតដ៏ពិសេសថ្លៃថ្លា ការខ្វះខាតនោះឯង គឺគឺលោះសរសើរការគោរពប្រណិប័តន៍ និងបញ្ជូលការគោរពសំពះថ្វាយបង្គំ (الصلاة) ហើយនិងការបរិច្ចាគទាន

البيّنة

ភស្តុតាងដ៏ច្បាស់លាស់

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

ដោយព្រះនាមអុលឡោះ ម្ចាស់ទ្រង់មហាសប្បុរស ទៀតទ្រង់មហាមេត្តាប្រណី ។

١ لَمْ يَكُنِ الَّذِيْنَ كَفَرُوْا مِنْ اَهْلِ الْكِتٰبِ وَالْمُشْرِكِيْنَ مُنْفَكِّيْنَ حَتّٰى تَأْتِيَهُمُ الْبَيِّنَةُ

១ បណ្ដាអ្នកគ្មានជំនឿ ពីអ្នកសាស្ត្របណ្ឌិតគម្ពីរ (ជ្វីហ្វនិងគ្រិស្តសាសនា គឺយ៉ាហ៊ូទី និងណាស-រ៉ានី) ហើយនិងអ្នកដែលលាបព្រះ (ពហុទេព) អ្នកទាំងនោះហើយ ដែលមិនព្រមបោះបង់ចោលសាសនារបស់គេឡើយ លុះត្រាតែបានដល់មកអ្នកទាំងនោះនូវភស្តុតាងដ៏ជាក់ច្បាស់ ។

٢ رَسُوْلٌ مِّنَ اللّٰهِ يَتْلُوْا صُحُفًا مُّطَهَّرَةً

២ នោះគឺ (មូហាំម៉ាត់) ជាអ្នកនាំសាររបស់អុលឡោះ ដែលបានសូត្រមហាគម្ពីរ ដ៏មហាបរិសុទ្ធ (រួចពីការក្លែង, ការបោកប្រាស់ ហើយនិងការក្លាកបញ្ឆោត) ។

٣ فِيْهَا كُتُبٌ قَيِّمَةٌ

៣. នៅក្នុងវានោះ មានក្បួនច្បាប់ទាំងឡាយ ដ៏មហាបរិសុទ្ធ (គីតាប) ។

٤ وَمَا تَفَرَّقَ الَّذِيْنَ اُوْتُوا الْكِتٰبَ اِلَّا مِنْ بَعْدِ مَا جَاۤءَتْهُمُ الْبَيِّنَةُ

៤ ហើយគ្មានបែកបាក់សាមគ្គីគ្នាទេ បណ្ដាអ្នកដែលគេ (អុលឡោះ) បានប្រទានគីតាបទៅលើអ្នកទាំងនោះ លើកលែងតែក្រោយពីបានដល់មកនូវភស្តុតាងដ៏មហាជាក់ច្បាស់ ។

٥ وَمَا اُمِرُوْا اِلَّا لِيَعْبُدُوا اللّٰهَ مُخْلِصِيْنَ لَهُ الدِّيْنَ

៥ ហើយគេពុំប្រើអ្នកទាំងអស់នោះទេ លើកលែងតែដើម្បីឲ្យអ្នកទាំងអស់នោះ គោរព

ការគោរពសំពះទៅចំពោះអល់ឡោះ
ដោយស្មោះត្រង់ ហើយតែងតែការពារនូវមាន
សាលសា និងបង្ហា យុត្តិធម៌ និងជឿប្រាកដទាំង
អស់នោះ បញ្ញារ ធ្វើការគោរពសំពះថ្វាយ
បង្គំ ទៀតនិងជឿប្រាកដទាំងអស់នោះ ធ្វើ
វិភាគទាន(الزكوة) ទៅនោះហើយ គឺជាសាសនា
និងបញ្ហា យុត្តិធម៌ ។

حنفاء ويقيموا الصلوة ويؤتوا الزكوة ذلك
دين القيمة

៦ ពិតប្រាកដ បណ្ដាអ្នកមិនលទ្ធនជំនឿ ពី
សាស្ត្រាបណ្ឌិតគម្ពីរ ហើយនិងបណ្ដាអ្នក
មិនលមានជំនឿជឿថា មានអល់ឡោះច្រើន
ទៀត មកប្រៀបធៀបនឹងអល់ឡោះ របស់
អល់ឡោះ ទៀតនោះ គង់តែនឹងចូលទៅ
ក្នុងភ្លើង នរក អវិជ្ជា យ៉ាងហិនហោច ជាប់
ជានិច្ច នៅក្នុងនោះ អ្នកទាំងអស់នោះ
ជាពពួក ដែលនឹងនរកាក្រក់អាក្រក់ជាទីបំផុត
ក្នុងលោកីយ ។

٦ إِنَّ الَّذِينَ كَفَرُوا مِنْ أَهْلِ الْكِتَبِ
وَالْمُشْرِكِينَ فِي نَارِ جَهَنَّمَ خَلِدِينَ
فِيهَا أُولَئِكَ هُمْ شَرُّ الْبَرِيَّةِ

៧. ពិតប្រាកដ បណ្ដាអ្នកមានជំនឿ ហើយ
បានប្រតិបត្តិនូវការល្អប្រសើរ អ្នកទាំង
នោះហើយ ជាពពួក មនុស្សប្រសើរបំផុត
ល្អ ក្នុងលោកីយនេះ ។

٧ إِنَّ الَّذِينَ آمَنُوا وَعَمِلُوا الصَّلِحَتِ
أُولَئِكَ هُمْ خَيْرُ الْبَرِيَّةِ .

៨ ការតបស្នងសង ចំពោះបណ្ដាអ្នកទាំង
នោះហើយ សំពីម្ចាស់របស់អ្នកទាំងនោះ
ផង គឺឋានសួគ៌ ស្ថានសុខ(عدن) ដែល

٨ جَزَاؤُهُمْ عِنْدَ رَبِّهِمْ جَنَّتُ عَدْنٍ تَجْرِي
مِنْ تَحْتِهَا الْأَنْهَرُ خَلِدِينَ فِيهَا

أَبَدًا رَضِيَ اللَّهُ عَنْهُمْ وَرَضُوا عَنْهُ ذَٰلِكَ لِمَنْ خَشِيَ رَبَّهُ

មានបារពីក្រោមវា មណ្ឌលទន្លេ
អ្នកទាំងអស់នោះ ស្ថិតនៅអាប់អានិរន្តរ៍
ដោយ អល់ឡោះ ម្ចាស់ទ្រង់បានទទួល
យល់ព្រម រវៀអ្នកទាំងអស់នោះ
(ពីព្រោះបានធ្វើគុណដែលនៅក្នុងលោកីយពីមុនមក)
ហើយ ទើប អ្នកទាំងអស់នោះ បានទទួល
ផលតាមស្មានដ៏ល្អ ពីទ្រង់ ដូចនោះឯង
គឺសំរាប់ អ្នកកោតខ្លាច ម្ចាស់របស់គេ ។

ប៊ិនតកប៉ាវិត្ត វគ្គនេះ បានបញ្ជាក់ ពីការបញ្ជារបស់ អល់ឡោះ ។
អល់ឡោះ បានបញ្ជាក់ ដោយច្បាស់លាស់ពិតប្រាកដ នូវការទូន្មាន របស់ សាវ៉ះ(លោកញ៉ូ) ម្ហូហាំម៉ាត់ នេះ គឺការទូន្មាន ដ៏ពិតប្រាកដដ៏គត់ល្អ ហើយនឹងសាសនា ដែល សាវ៉ៈ(លោកញ៉ូ) ម្ហូហាំម៉ាត់ បាននាំមកនោះ គឺសាសនា ដ៏ត្រឹមត្រូវ ជាទីបំផុត ដែលពេញលក្ខណៈ នូវគោលការណ៍ទូន្មាន ដោយ មានសព្វគ្រប់នៃច្បាប់ទំលាប់ទូន្មាន របស់ សាវ៉ៈ (លោកញ៉ូ) ពីមុនៗមក ។

រាត្រីដ៏មហាថ្កុំថ្កើង القَدْرُ

កំណើតវគ្គ វគ្គនេះបានបញ្ចុះនៅម៉ាក្កាស់ ហើយមាន ៥ ឃ្លា ។
គេបានបញ្ចុះវគ្គនេះក្រោយពីពេលដែលគេបានបញ្ចុះវគ្គ عبس
ឈ្មោះ القدر មានន័យថា រាត្រីដ៏មហាថ្កុំថ្កើង
គេយកមកអំពីពាក្យសំដី القدر ដែលមាននៅក្នុងឃ្លា
ដំបូងបង្អស់នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

អាល់គួរអាន (القرآن) ដែលមហាថ្កុំថ្កើងនេះ គេបានបញ្ចុះនៅពេលរាត្រីដ៏មហាថ្កុំថ្កើង ដោយមានការល្អលើសលប់ជាងខែមួយពាន់ខែទៅទៀត ។ រាត្រីនោះពពួកទេវៈ(ម៉ាឡាអ៊ីកាត់) រួមទាំងទេវៈជិប្រូអេល បានចុះមកលើលោកិយនេះ ដើម្បីរៀបចំអ្វីៗ កិច្ចការនានា ។

القَدْرُ
រាត្រីដ៏មហាថ្កុំថ្កើង

ដោយព្រះនាមអល់ឡោះ ម្ចាស់ដ៏មហា
សាណាអាណិតស្រឡាញ់ដ៏មហាមេត្តាប្រណី ។

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

១. ពិតប្រាកដយើង (អល់ឡោះ) បានបញ្ចុះ
ហើយវា [អាល់គួរអាន (القرآن)] នាពេល
រាត្រីដ៏មហាថ្កុំថ្កើង ។

إِنَّا أَنزَلْنَاهُ فِي لَيْلَةِ الْقَدْرِ ١

២. ហើយអ្នកឯងបានដឹងដែរឬទេ អ្វីទៅការត្រីមហាថ្កុំថ្កើងនោះ?	٢ وَمَا أَدْرَاكَ مَا لَيْلَةُ الْقَدْرِ
៣ រាត្រីមហាថ្កុំថ្កើងនោះ ល្អវិសេសបំផុត លើសជាង មួយពាន់ខែ	٣ لَيْلَةُ الْقَدْرِ خَيْرٌ مِنْ أَلْفِ شَهْرٍ
៤ បានចុះហើយពពួកទេវតា [ម៉ាឡាអ៊ីកាត់ (ملائكة)] និងមួយទេវតា បរិសុទ្ធ (ملائكة جبريل) នាពេលរាត្រីនោះ ដោយការយល់ស្រប ពីម្ចាស់របស់វា (ពួកម៉ាឡាអ៊ីកាត់) សំរាប់រៀបចំកិច្ចការទាំងអស់ នោះ ។	٤ تَنَزَّلُ الْمَلَائِكَةُ وَالرُّوحُ فِيهَا بِإِذْنِ رَبِّهِمْ مِنْ كُلِّ أَمْرٍ
៥. នាពេលរាត្រីនោះហើយ ពោរពេញទៅដោយប្រិយភាពសុខសាន្ត រហូតដល់តែចេញរស្មីហ្វាយជ័រ [الفجر] (រស្មីក្រហមព្រឿងដ៏ភ្លឺ ។.	٥ سَلَامٌ هِيَ حَتَّىٰ مَطْلَعِ الْفَجْرِ

បរិកថាវិគ្គ វគ្គនេះបានបញ្ជាក់ យ៉ាងច្បាស់លាស់ ពីដំណើរការណ៍ ដែលគេបញ្ចុះ គម្ពីរគួរអាន (القرآن) នៅវេលាយប់ ឡៃឡាតុលកឌ័រ (ليلة القدر) ហើយគេបានបញ្ជាក់ ពីសភាពរុងរឿង ដ៏ថ្កុំថ្កើងនៃវេលារាត្រីនោះ ។

ឈាមមួយដុំ الْعَلَق

កម្ពុជាវិត្ត វគ្គនេះគេបានបញ្ចុះ នៅម៉ិកកាស់ ដែលមាន១៩ឃ្លា ។ ពាក្យពីឃ្លាទី១ ទៅដល់ឃ្លាទី៥ ពាក្យវគ្គនេះគេបាន បញ្ចុះជា ដំបូងបង្អស់នៅក្នុងគម្ពីរ អាល់គួរអាន(القران) ។ នាពេលនោះ ហើយ គឺជាពេលដែល ណាប៊ី(ណាព្វី) មូហាំម៉ាត់ បានលាក់ខ្លួន សំណាក់ នៅក្នុងភ្នំ ហ៊ីរ៉ក

ឈ្មោះ العلق មានន័យថា ឈាមមួយដុំ

គេបានយកពាក្យសំដី العلق ដែលមាននៅក្នុងឃ្លាទី២ នៃវគ្គ នេះ ។

គេហៅឈ្មោះទៀត اقرأ ឬ القلم

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

សេចក្តីបញ្ជាក់ :

- បញ្ជាអោយសូត្រ គួរអាន
- មនុស្សលោក គេបានបង្កើតមកពីឈាមមួយដុំ
- ហើយអល់ឡោះ បានបង្កើត ការប្រើ កន្លាម (القلم) និងប៉ាក សំរាប់សរសេរ ដើម្បីជាប្រយោជន៍ សំរាប់ ពង្រីកមនោគមន៍វិជ្ជា ដែលនៅតាមមនុស្សប្រព្រឹត្តទៅពីលើលោក ហើយយល់ឃើញ ហេតុមក ពីយល់ឃើញថា ខ្លួនរបស់គេនោះ មានបានសព្វគ្រប់គ្រាន់ខ្លួនរួច ទៅហើយ ។

អល់ឡោះ បានធ្វើទុក្ខបុកម្នេញ ទៅដល់ពោះបណ្តាអ្នកដែលគ្មាន ជំនឿនោះ អ្នកណាដែល បានប្រឆាំងការងារ នៅឯបណ្តាក្រុមសាសនា ដែលបាន អនុវត្តតាមប្រតិបត្តិ តាមបញ្ជារបស់អល់ឡោះជាម្ចាស់ ។

ឈាមមួយដុំ الْعَلَق

بِسْمِ اللَّهِ الرَّحْمَنِ الرَّحِيمِ

នឹងព្រះនាមអុលឡោះ ម្ចាស់ទ្រង់មហាសាការុណ្យ ទៀតទ្រង់មហាមេត្តាប្រណី។

١ اقْرَأْ بِاسْمِ رَبِّكَ الَّذِي خَلَقَ

១. ចូរសូត្រចុះ (ឱ មូហាំម៉ាត់) នឹងព្រះនាមម្ចាស់ឯង ដែលបានបង្កើតវត្ថុនានា គ្រប់សព្វាកិ សព្វសារពើ ។

٢ خَلَقَ الْإِنْسَانَ مِنْ عَلَقٍ

២. ទ្រង់នោះហើយ បានបង្កើតមនុស្សលោក អំពីឈាមមួយដុំកោហាត ។

٣ اقْرَأْ وَرَبُّكَ الْأَكْرَمُ

៣ ចូរសូត្រចុះ (ឱ មូហាំម៉ាត់) នឹងព្រះនាមម្ចាស់ឯង ដ៏មហាថ្កុំថ្កើង

٤ الَّذِي عَلَّمَ بِالْقَلَمِ

៤ ទ្រង់នោះហើយ បានបង្រៀន (សរសេរ) នឹងស្លាបប៉ាកា ។

٥ عَلَّمَ الْإِنْسَانَ مَا لَمْ يَعْلَمْ

៥ ទ្រង់បានបង្រៀនមនុស្សលោក នូវរឿងដែលគេពុំបានដឹង ។

٦ كَلَّا إِنَّ الْإِنْسَانَ لَيَطْغَى

៦. ពិតចុះ ពិតប្រាកដ មនុស្សលោកនោះ ហើយ រំលោភមហាទុច្ចរិត ។

៧. ពីព្រោះវាបានឃើញលើខ្លួនវាថា: បរិបូណ៌គ្រប់បែបយ៉ាង ។ | ٧ أَن رَّآهُ اسْتَغْنَىٰ

៨ ពិតប្រាកដ ទៅកាន់ព្រះម្ចាស់របស់វានោះ ហើយ ដែលវានឹងវិលត្រឡប់ ។ | ٨ إِنَّ إِلَىٰ رَبِّكَ الرُّجْعَىٰ

៩. តើអ្នកនឹងបានឃើញដឹងឬទេ? អ្នកដែលហាមឃាត់ ។ | ٩ أَرَأَيْتَ الَّذِي يَنْهَىٰ

១០. ខ្ញុំរបស់អល់ឡោះ ពេលណាដែលវា សំពះគោរពប្រតិបត្តិ (សឡះ: صلاة) | ١٠ عَبْدًا إِذَا صَلَّىٰ

១១ តើអ្នកនឹងបានយល់ដូចម្ដេចដែរ? បើប្រសិនណាជា អ្នកដែលត្រូវគេហាមឃាត់នោះ នៅលើផ្លូវដែលត្រឹមត្រូវ? | ١١ أَرَأَيْتَ إِن كَانَ عَلَى الْهُدَىٰ

១២. ឬមួយជាវា បានបញ្ជាប្រើគេឲ្យធ្វើការណាដែលកោតខ្លាច ។ | ١١ أَوْ أَمَرَ بِالتَّقْوَىٰ

១៣. តើអ្នកនឹងបានយល់ដូចម្ដេចដែរ បើប្រសិនណា អ្នកហាមឃាត់គេនោះ ជាអ្នកដែលភូតភរកុហក ហើយបានបែរទៅជាក្បត់ទៀត | ١٢ أَرَأَيْتَ إِن كَذَّبَ وَتَوَلَّىٰ

១៤ តើវាបាននឹងដឹងទេឬ? ថាពិតប្រាកដ អល់ឡោះនោះហើយជាម្ចាស់ដែលមហាឃើញ (អ្វីៗដែលវាបានប្រព្រឹត្ត) | ١٤ أَلَمْ يَعْلَم بِأَنَّ اللَّهَ يَرَىٰ

១៥ កុំក្អើងចំពោះ ប្រាកដណាស់ទៅហើយ បើប្រសិនណាគាត់ពុំព្រមលះបង់ទេ នោះ ព្រោះដាច់ហើយនឹងទាញយក បង្ហើយក្បាលរបស់គាត់ ។ — ١٥ كَلَّا لَئِن لَّمْ يَنتَهِ لَنَسْفَعًا بِالنَّاصِيَةِ

១៦ នោះគឺ ក៏បង្ហើយក្បាលអ្នកដែលភូត ភរ កុហក ទៀតអ្នកដែលមានកំហុស ។ — ١٦ نَاصِيَةٍ كَاذِبَةٍ خَاطِئَةٍ

១៧ ដើម្បីឲ្យ ចូរឲ្យគាត់ហៅចុះទៅក្រុមគណៈ បក្សរបស់គាត់ (សំរាប់ជួយព្រោះដើម្បីឲ្យ) — ١٧ فَلْيَدْعُ نَادِيَهُ

១៨ យើងនឹងហៅ ទេវតាម៉ាឡាអ៊ីកាត់ (زبانية. ملائكة الزبانية) (ទេវតាអ្នកដែល យាមឋាននរក) ។ — ١٨ سَنَدْعُ الزَّبَانِيَةَ

១៩. ចូរអ្នកឯង (មូហាំម៉ាត់) កុំប្រណិប័តន៍ តាមគាត់ដោយនោះ ទៀតចូរអ្នកឯង គោរពចុះ (ចំពោះ អល់ឡោះ) ហើយ ភ្ជិតខ្លួនអ្នកឯងចុះ (ចំពោះ អល់ឡោះ) ។ — ١٩ كَلَّا لَا تُطِعْهُ وَاسْجُدْ وَاقْتَرِبْ

ឋិតកញ្ចាង្គ វគ្គនេះបានបញ្ជាក់ថា៖
អល់ឡោះ បានបង្កើតមនុស្សលោក ពីទឹកកំណើតដែល សមរម្យ ខ្ពង់ខ្ពស់ ។
បន្ទាប់មកទៀតបានលើកយកទឹង មនុស្សលោកនោះ និងបង្រៀន

ដោយខ្វះខាត , ខ្វះសារសៃ ហើយនិងធ្វើការបង្ខំខ្លួន មកការពារ
វិជ្ជាស្ទៀងៗ ក៏ប៉ុន្តែមនុស្សលោកគេ គ្មានគិតគិត ឃើញទេ អំពីលើ
កំណើតរបស់ខ្លួនទេនោះ ដោយលោភលន់វក់វីអ្នកទាំងនោះគ្មានគិតគិត
ពីប្លង់ស្ដីអំណរអំរគុណ ចំពោះការបូជាន ដោយគម្ពីររបស់ព្រលឹងព្រះជា
ម្ចាស់ ។ ផ្ទុយទៅវិញ អ្នកទាំងនោះគ្រប់ ទៅជាប្រពន្ធ អាវ
យំស្ដែងកញ្ច្រោងបង្វែរ ទៅវិញ ដោយលោភលន់វក់វី យល់ឃើញថា :
ខ្លួនគេនោះ ស្ថិតនៅក្នុងការគ្រប់គ្រងតែប៉ុណ្ណោះ ។

ផ្លែទីន التين

អំពីវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ៨ ឃ្លា ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ بروج ។
ឈ្មោះ التين មានន័យថា ផ្លែទីន ។
គេយកមកពីពាក្យសំដី التين ដែលមាននៅក្នុងឃ្លាដំបូងបង្អស់នៃវគ្គនេះ

